គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ២ ចេញផ្សាយថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១
No. 2 Released on July 12, 2021

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# តើបរធនបាលកិច្ចជាអ្វី?

## What Is A Trust?




រូបភាព | Picture:
https://cdn.corporatefinanceinstitute.com/assets/trust-bank1-1024x611.jpeg

បរធនបាលកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលបរធនបាលទាយក ផ្តល់ទ្រព្យសម្បត្តិដល់បរធនបាលក្នុងការមើលថែរក្សា និងប្រើប្រាស់ជាប្រយោជន៍ដល់អត្ថគាហកៈ។ ជាទូទៅ ភាគីនៃបរធនបាលកិច្ចជាសំខាន់មាន៣ (បី) គឺបរធនបាលទាយក បរធនបាល និងអត្ថគាហកៈ។ បរធន-បាលកិច្ចត្រូវបានបង្កើតឡើងដោយបរធនបាលទាយក ឬបទប្បញ្ញត្តិជាធរមាន និងត្រូវមានកម្មវត្ថុស្របច្បាប់ និងមិនផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ។ ទំនាក់ទំនងនេះ គឺជាកាតព្វកិច្ចដែលចែងដោយច្បាប់ក្នុងការតម្រូវឱ្យបរធនបាលមានសិទ្ធិកាន់កាប់ និងគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់ជាប្រយោជន៍ ដល់បុគ្គលដែលនឹងត្រូវទទួលបានអត្ថប្រយោជន៍ពីទ្រព្យសម្បត្តិនោះ (*យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០១៦-២០២៥*, ២០១៦; *ច្បាប់ស្តីពីបរធនបាលកិច្ច*, ២០១៩)។ ដំណើរការនៃការបង្កើតបរ-ធនបាលកិច្ចមានដូចជា៖ ១. ករណីដែលបរធនបាលកិច្ចត្រូវបានបង្កើតឡើងដោយបរធនបាលទាយក បរធនបាលទាយកត្រូវផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិរបស់ខ្លួនទៅឱ្យបរធនបាល តាមរយៈលិខិតបរធនបាលកិច្ច ដោយមានបញ្ជាក់ពីគោលបំណងជាក់លាក់របស់បរធនបាលកិច្ច និង/ ឬបញ្ជាក់ពីអត្តសញ្ញាណអត្ថគាហកៈ។ ២. ករណីដែលបរធនបាលកិច្ចត្រូវបានបង្កើតឡើងដោយបទប្បញ្ញត្តិជាធរមាន បរធនត្រូវបានផ្ទេរដោយស្វ័យប្រវត្តិឱ្យទៅបរធនបាល ដើម្បីគ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិស្របតាមបទប្បញ្ញត្តិជាធរមាន ដោយមានបញ្ជាក់ពីគោលបំណងជាក់-លាក់របស់បរធនបាលកិច្ចនិង/ ឬបញ្ជាក់ពីអត្តសញ្ញាណអត្ថគាហកៈ។ បរធនបាលកិច្ចមានអានុភាពអនុវត្ត នៅពេលដែលបរធនបាលយល់ព្រមទទួលយកជាលាយលក្ខណ៍អក្សរចំពោះការតែងតាំង (*ច្បាប់ស្តីពីបរ-ធនបាលកិច្ច*, ២០១៩) ។

A trust is a legal relationship whereby someone (the trust creator) gives property to someone (the trustee) to look after and use it for the benefit of someone (the beneficiary). In general, there are three (3) main parties to the trust: the trust creator, the trustee, and the beneficiary. A trust is established by the trust creator or provisions in force and must be legally binding and not contrary to public order. The relationship places legally enforceable obligations on the person holding the property to manage it for the benefit of the person entitled to receive the benefits of the property (Financial Sector Development Strategy 2016-2025, 2016; Trust Law, 2019). The process of establishing a trust is as follows: 1. In the case where the trust is established by the trust creator, the trust creator shall transfer its assets or funds to the trustee through a letter of trust stating the specific purpose of the trust and / or identifying the identity of the beneficiary. 2. In the case where the trust is established by the provisions in force, the asset or fund is automatically transferred to the trustee to manage and dispose of the assets in accordance with the provisions in force, stating the specific purpose of the trust and / or identifying the identity of the beneficiary. The trust has the power to act when the trustee agrees in writing to the appointment (*Trust Law*, 2019).

**អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References**:

- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០១៦-២០២៥. ២០១៦.
- ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

www.facebook.com/trustregulatorcambodia
អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh